# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៚៛៙

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ រវាង

លោក ស៊ិន សារ៉េត កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០៥០៨៥៥៩៥៦ ដែលមានតួនាទី **ប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **ហ្វ៊ូដឡាយហ្វ៍ ឯ.ក** ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ២៥ ផ្លូវ៥២៨ កែងផ្លូវ២៨៣ សង្កាត់បឹងកក់១ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

និង

លោក ហេង ថាន់ កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០២០៩៣១០៩៤ ដែលមានតួនាទីជា **មេផ្នែកចុងភៅ** និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**០១- រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

**០២- ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

**០៣- កាលបរិច្ឆេទចូលបម្រើការងារវិញ៖**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១

តំណាងភាគីនិយោជិក　　　　　　　　តំណាងភាគីនិយោជក

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ហ្វ៊ូដឡាយហ្វ៍ ឯ.ក
FOODLIFE CO., LTD.
KINGDOM OF CAMBODIA

លោក ហេង ថាន់　　　　　　　　លោក ស៊ិន សារ៉េត